ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...០៤...សសរ.

សេចក្តីសម្រេច

ស្តីពី

ការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីតាក់តែង សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាឱ្យដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងលិខិត ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៤ របស់ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

សំរេច

ប្រការ១.– បង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ ដែលមានសមាសភាពដូចតទៅ ÷

១- សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ	សហប្រធាន
២- រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី	អនុប្រធាន
៣- រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	អនុប្រធាន

www.pheakdeylaw.com

៤- រដ្ឋមន្ត្រី ក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក

៥- រដ្ឋមន្ត្រី ក្រសួងផែនការ សមាជិក

៦- រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម សមាជិក

៧- រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ សមាជិក

៨- រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា សមាជិក

៩- រដ្ឋមន្ត្រី ក្រសួងបរិស្ថាន សមាជិក

១០- រដ្ឋមន្ត្រី ក្រសួងសុខាភិបាល សមាជិក

១១- រដ្ឋមន្ត្រី ក្រសួងទេសចរណ៍ សមាជិក

១២- រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល សមាជិក

១៣- រដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន សមាជិក

១៤- រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សមាជិក

១៥- រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី សមាជិក

១៦- រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក

១៧- រដ្ឋមន្ត្រី ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

១៨- រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សមាជិក

១៩- ឯកឧត្តមប្រធានក្រុមការងាររៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការ សមាជិក

ប្រការ២.- គណៈកម្មការអន្តរក្រសួងនេះ មានតួនាទី ភារកិច្ចដូចខាងក្រោម ÷

- ប្រមែប្រមូលព័ត៌មានទាំងឡាយដែលបំរើឱ្យការរៀបចំសេចក្តីព្រាងច្បាប់

- ប្រមែប្រមូលអនុសាសន៍ពាក់ព័ន្ធ និង ការកែទំរង់អភិបាលកិច្ចនៅថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ ពីគ្រប់មជ្ឈដ្ឋាន ទាំងជាតិ អន្តរជាតិ សង្គមស៊ីវិល និង ដៃគូអភិវឌ្ឍន៍នានា ដើម្បីពិចារណាផ្តួចផ្តើម រៀបចំក្របខ័ណ្ឌគោលនយោបាយ និង ច្បាប់ស្តីពីការគ្រប់គ្រងខេត្ត ក្រុង ស្រុក ខណ្ឌ ។

- សិក្សាពិចារណា និង ផ្តល់យោបល់ដល់រាជរដ្ឋាភិបាល អំពីកំណែទំរង់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ ។

- បង្កើតឱ្យមានវេទិកា ពិគ្រោះយោបល់អំពីក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌច្បាប់ទាំងនេះក្នុងចំណោមតួអង្គពាក់ព័ន្ធនានា ។

- ដាក់សេចក្តីព្រាងច្បាប់ ជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យអនុម័ត ។

- សហការជាមួយទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីរៀបចំបែបបទដាក់សេចក្តីព្រាងច្បាប់នេះ ជូនរដ្ឋសភា។

www.pheakdeylaw.com

ប្រការ៣.– ត្រូវបានបង្កើតក្រុមការងារមួយសំរាប់ជាជំនួយការឱ្យគណៈកម្មការអន្តរក្រសួងនេះ ដែលមានសមាសភាពដូចខាងក្រោម ÷

១- ឯកឧត្តម **ព្រុំ សុខា**	រដ្ឋលេខាធិការក្រសួងមហាផ្ទៃ	ប្រធាន
២- ឯកឧត្តម **ឥង់ ប៊ុនឆរិទ្ធ**	រដ្ឋលេខាធិការក្រសួងមហាផ្ទៃ	អនុប្រធាន
៣- ឯកឧត្តម **នុត សាអាន**	រដ្ឋលេខាធិការក្រសួងមហាផ្ទៃ	អនុប្រធាន
៤- ឯកឧត្តម **សក់ សេដ្ឋា**	អគ្គនាយករដ្ឋបាល ក្រសួងមហាផ្ទៃ	សមាជិក
៥- អគ្គនាយក ឬ អគ្គនាយករង	នៃក្រសួងសមាជិកគណៈកម្មការ	សមាជិក

គណៈកម្មការអាចចាត់មន្ត្រីពីក្រសួង ស្ថាប័ន ក្នុងគណៈកម្មការឱ្យចូលរួមជាសមាជិកក្រុមការងារបន្ថែមទៀតតាមការចាំបាច់ ។

តួនាទី ភារកិច្ច និង របៀបរបបការងាររបស់ក្រុមការងារខាងលើនេះ ត្រូវកំណត់ដោយសេចក្ដីសំរេចរបស់គណៈកម្មការ ។

ប្រការ៤.– ក្រុមការងាររៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រ ស្ដីពីវិមជ្ឈការ និងវិសហមជ្ឈការ ត្រូវភ្ជាប់ការងាររបស់ខ្លួនជាមួយគណៈកម្មការនេះ ដើម្បីរៀបចំសេចក្ដីព្រាងក្របខ័ណ្ឌគោលនយោបាយជូនរាជរដ្ឋាភិបាល ពិនិត្យសំរេច ។

ប្រការ៥.– គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិអញ្ជើញថ្នាក់ដឹកនាំ តំណាងក្រសួងស្ថាប័នផ្សេងទៀតដែលមិនស្ថិតក្នុងសមាជិកគណៈកម្មការ ដើម្បីចូលរួមប្រជុំពិភាក្សា និង សហការបំពេញការងារតាមការជាក់ស្ដែង ។

គណៈកម្មការមានសិទ្ធិចាត់ចែង ប្រើប្រាស់មន្ត្រីរាជការនៃទីស្ដីការក្រសួងមហាផ្ទៃ និង អាចស្នើសុំមន្ត្រីជំនាញពីក្រសួង ស្ថាប័ននានា ដែលជាសមាជិកគណៈកម្មការឱ្យចូលរួមជួយការងារតាមការចាំបាច់ បន្ទាប់ពីមានការឯកភាពពីក្រសួង ស្ថាប័នសាមី នៃមន្ត្រីទាំងនោះ ។

គណៈកម្មការអាចស្នើចាត់បញ្ជូនសមាជិកគណៈកម្មការ ឬសមាជិកក្រុមការងាររបស់ខ្លួន ឱ្យទៅធ្វើទស្សនកិច្ចសិក្សាដកពិសោធន៍នៅបរទេសតាមការចាំបាច់ បន្ទាប់ពីបានការយល់ព្រមពីប្រមុខរាជរដ្ឋាភិបាលកម្ពុជា ។

ប្រការ៦.– សមាជិកទាំងអស់នៃគណៈកម្មការអន្តរក្រសួងនេះ ត្រូវអញ្ជើញចូលរួមប្រជុំ និងធ្វើការងារតាមសេចក្ដីអញ្ជើញ និង ការណែនាំរបស់សហប្រធាន ។

www.pheakdeylaw.com

ប្រការ៧.- គណៈកម្មការអន្តរក្រសួងនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ ។

ប្រការ៨.- ថវិកា សំភារៈ សំរាប់បំពេញការងាររបស់គណៈកម្មការត្រូវប្រើប្រាស់ក្នុងថវិកាផ្នែករដ្ឋបាលស៊ីវិលនៃក្រសួងមហាផ្ទៃ ។

គណៈកម្មការអាចស្នើសុំ ឬទទួលជំនួយឧបត្ថម្ភផ្នែកបច្ចេកទេស ហិរញ្ញវត្ថុ និង សំភារៈ ពីប្រភពក្នុងស្រុក និងអន្តរជាតិ សំរាប់គាំទ្រដល់ការតាក់តែងសេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ ។

ប្រការ៩.- គណៈកម្មការនេះនឹងត្រូវបញ្ចប់អាណត្តិនៅពេលដែលច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ ចូលជាធរមាន ។

ប្រការ១០.- ក្រសួង ស្ថាប័នទាំងអស់នៃរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង ស្ថាប័ន ដូចដែលមានចែងក្នុងប្រការ១ និង ប្រការ៣ ត្រូវអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ មករា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ១០
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com